Australian Government

counselling help support cooperative safe children develop confidential improve

# ជួយឪពុកម្ដាយនានាក្រោយការបែកគ្នា

នៅទីណាដែលគ្រួសារនានាដែលបែកបាក់ស្ថិតនៅក្នុងជម្លោះខ្លាំងទៅលើការរៀបចំចាត់ចែងធ្វើជាឪពុកម្ដាយ រដ្ឋាភិបាលអូស្ត្រាលីបានផ្ដល់មូលនិធិដល់កម្មវិធីជីកាបង្គាប់ ឪពុកម្ដាយ និងសេវានានាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នានៅទូទាំងប្រទេសអូស្ត្រាលី ដើម្បីជួយឪពុកម្ដាយនានាអោយផ្ដោតការយកចិត្តទុកដាក់ទៅលើ កូនៗរបស់ពួកគេ។

## តើអ្វីទៅជា កម្មវិធីជីកាបង្គាប់ឪពុកម្ដាយ និងសេវានានាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា?

កម្មវិធីជីកាបង្គាប់ឪពុកម្ដាយ និងសេវានានាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា គឺជាកម្មវិធីធ្វើជាឪពុកម្ដាយក្រោយការបែកគ្នាដែលស្ថិតនៅក្រោមមាត្រាច្បាប់គ្រួសារ។ កម្មវិធីនិងសេវាទាំងនេះជួយឪពុកម្ដាយដែលបានបែកគ្នា ដែលស្ថិតនៅក្នុងជម្លោះខ្លាំង រៀនសូត្រពីរបៀបដែលជម្លោះ ឪពុកម្ដាយប៉ះពាល់ដល់កូនៗ និងហេតុផលដែលកូនៗត្រូវការឪពុកម្ដាយជួយឧបត្ថម្ភគាំទ្រនៃទំនាក់ទំនងរបស់ពួកគេជាមួយនឹងឪពុកម្ដាយដទៃទៀត។ កម្មវិធីនិងសេវាទាំងនេះជួយឪពុកម្ដាយនានាអោយផ្ដោតការយកចិត្តទុកដាក់ទៅលើសេចក្ដីត្រូវការរបស់កូនជាជាង ជម្លោះ និងគិតគូរធ្វើការរៀបចំចាត់ចែងនានាដែលអនុញ្ញាតិអោយឪពុកម្ដាយនិងសមាជិកគ្រួសារដទៃទៀត ដើម្បីចំណាយពេលជាមួយកូន។

## ហេតុអ្វីបានជាត្រូវទៅរក កម្មវិធីដីកាបង្គាប់ ឪពុកម្តាយ ?

ពេលខ្លះគ្រួសារទាំងឡាយដែលបានបែកគ្នាមិនអាចយល់ព្រមស្តីពីការរៀបចំចាត់ចែងសំរាប់ជួបកូនៗរបស់ពួកគេ និង មិនអាចធ្វើអោយដីកាបង្គាប់ឪពុកម្តាយដំណើរបាន។
ឪពុកម្តាយអាចបានទៅតុលាកាដើម្បីបានធ្វើដីកាបង្គាប់ឪពុកម្តាយ
ក៏ប៉ុន្តែមានបញ្ហានៅក្នុងការអនុវត្តន៍តាមដីកាបង្គាប់ទាំងនោះ។ កម្មវិធីដីកាបង្គាប់
ឪពុកម្តាយអាចជួយឪពុកម្តាយដឹងឮស្តីពី អ្វីដែលកូនៗចង់បាន និងត្រូវការនៅដំណាក់កាលនិងអាយុៈ
ផ្សេងៗគ្នានៃការ
វិវត្តន៍របស់ពួកគេ។

## ហេតុអ្វីបានជាត្រូវទៅសេវាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នា ?

ឪពុកម្តាយដែលបានបែកគ្នាជាច្រើនដឹងថាជម្លោះរវាងពួកគេគឺធ្វើអោយកូនរបស់ពួកគេមិនសប្បាយចិត្ត
ក៏ប៉ុន្តែមានអារម្មណ៍ថាគ្មានអ្វីដែលពួកគេអាចធ្វើបាន។ កូនអាចពុះពារខាងមនោសញ្ចេតនា
បើទោះបីជាពួកគេមើលទៅដូចជាមិនអីនៅលើផ្ទៃមុខ។
សេវាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នាអាច
ជួយលោកអ្នករៀនសូត្រពីអ្វីដែលកូនៗត្រូវការក្រោយឪពុកម្តាយរបស់ពួកគេបានបែកគ្នា
និងស្វែងរកវិធីនានាដើម្បីជួយ កូនរបស់លោកអ្នក។

សេវាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នាគឺមិនមែនស្តីពីការដោះស្រាយជម្លោះជាមួយនឹងឪពុកម្តាយ ដទៃទៀតទេ។ វាស្តីអំពីជម្លោះរវាងឪពុកម្តាយដែលបានបែកគ្នាប៉ះពាល់ដល់ កូនៗ និងពីអ្វីដែលលោកអ្នក ជាបុគ្គល អាចធ្វើវាបាន។ វាជួយលោកអ្នកស្វែងរករបៀបដែលលោកអ្នកអាចជួយកូនរបស់លោកអ្នក មិនថាកូននោះរស់នៅ ឬមិនរស់នៅជាមួយ លោកអ្នកទេ។

## តើកម្មវិធីដីកាបង្គាប់ឪពុកម្តាយមានរយៈពេលប៉ុន្មាន ?

កម្មវិធីដីកាបង្គាប់ឪពុកម្តាយអាចធ្វើការជាមួយឪពុកម្តាយ នានាបានយូរទៅតាមពួកគេត្រូវការ។ នេះអាចបីខែ ឬវាអាចរហូតដល់ទៅពីរឆ្នាំ។

## តើ ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នាមានរយៈពេលប៉ុន្មាន ?

សិក្ខាសាលាអប់រំនឹងចំណាយពេលជាធម្មតាកន្លះថ្ងៃ។ ក្រោយមកទៀត សេវានានាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នា អាចផ្តល់នូវការពិគ្រោះយោបល់ និងការជួយឧបត្ថម្ភបន្ថែមទៀត។ នេះអាចពីរបីសប្តាហ៍ ឬច្រើនខែ។

## តើមានអ្វីកើតមាន ប្រសិនបើលោកអាចមានអារម្មណ៍មិនមានសុវត្ថិភាព ?

កម្មវិធីជីកាបង្គាប់ឪពុកម្តាយ និងសេវានានាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នាមានការរៀបចំចាត់ចែងនានាកើតមានឡើងដើម្បីការពារសុវត្ថិភាពរបស់អតិថិជន និងបុគ្គលិក។ ប្រសិនបើលោកអ្នកមានការព្រួយបារម្ភស្តីពីសុវត្ថិភាពរបស់លោកអ្នក ឬសុវត្ថិភាពរបស់កូនរបស់លោកអ្នក លោកអ្នកត្រូវអោយបុគ្គលិកសេវាដឹងអោយបានលឿនដែលអាចធ្វើទៅបាន។

## ហេតុអ្វីបានជាកូនត្រូវមានសុវត្ថិភាព ?

សុវត្ថិភាពរបស់សមាជិកគ្រួសារទាំងអស់គឺសំខាន់ណាស់ នៅក្នុងកម្មវិធីជីកាបង្គាប់ឪពុកម្តាយ និងសេវានានាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នា។ សូមពិភាក្សារឿងនេះជាមួយនឹងបុគ្គលិក។

## តើនរណាខ្លះដែលអាចទៅរក កម្មវិធីជីកាបង្គាប់ឪពុកម្តាយ និងសេវានានាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នា ?

ឪពុកម្តាយដែលបានបែកគ្នាដែលមិននិយាយ ឬមានបញ្ហាជាមួយនឹងការរៀបចំចាត់ចែងធ្វើជាឪបុកម្តាយ ឬជាមួយនឹង ជីកាបង្គាប់តុលាការ អាចទៅរកកម្មវិធីជីកាបង្គាប់ឪពុកម្តាយ។ លោកអ្នកអាចចូលរួមនៅក្នុងកម្មវិធីខ្លះដោយខ្លួនរបស់លោកអ្នកផ្ទាល់ ឬលោកអ្នកអាចចូលរួមក្នុងនាមជាគូស្រករ ឬជា គ្រួសារ។ កូនៗរបស់លោកអ្នកក៏អាចចូលរួមពាក់ព័ន្ធផងដែរ។

ឪពុកម្ដាយដែលបានបែកគ្នាដែលមិនអាចធ្វើទំនាក់ទំនង ដោយគ្មានការវាយប្រតប់ក៏អាចទៅរកសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា បានដែរ។ សេវានានានឹងរៀបចំចាត់ចែងសំរាប់ឪពុកម្ដាយទាំងឡាយ ដើម្បីចូលរួមនៅឯពេលវេលាដាច់ដោយឡែក ដូច្នេះពួកគេ មិនត្រូវជួបគ្នាទេ។ កម្មវិធីគឺសំដៅទៅលើឪពុកម្ដាយទាំងពីរជាបុគ្គល និងអាចជួយបាន ទោះបីឪពុកម្ដាយតែម្នាក់ចូលរួមក៏ដោយ។

## តើមានអ្វីកើតឡើងនៅក្នុងអំឡុងកម្មវិធីជីកាបង្គាប់ ឪពុកម្ដាយ?

មានរឿងមួយចំនួនដែលអាចកើតឡើងជាផ្នែកនៃកម្មវិធីជីកាបង្គាប់ឪពុកម្ដាយ។ ទាំងនេះរួមមានការនិយាយជាមួយអ្នកពិគ្រោះយោបល់ គ្រួសារ ការចូលរួមសិក្ខាសិលាព័ត៌មាន ការចូលរួមនៅក្នុងក្រុមអប់រំជាមួយនឹងឪពុកម្ដាយដទៃទៀតដែលកំពុងមាន បញ្ហាដូចគ្នា និងប្រសិនបើឪពុកម្ដាយទាំងពីរមានឆន្ទៈ សាកល្បងដំណោះស្រាយជម្លោះគ្រួសារ។

## តើមានអ្វីកើតមានឡើងនៅឯសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា?

មានរឿងជាច្រើនដែលអាចកើតមានជាផ្នែកនៃសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា។ វានឹងតែងតែមានសិក្ខាសាលាអប់រំជាមួយនឹងឪពុកម្ដាយដទៃទៀតដែលកំពុងមានបញ្ហាដូចគ្នា។ អ្នកពិគ្រោះយោបល់គ្រួសារក៏នឹងផ្ដល់ការជួយឧបត្ថម្ភដទៃទៀតផងដែរ អាស្រ័យទៅតាមសេចក្ដីត្រូវការរបស់លោក អ្នក។ សេវានឹងពន្យល់ពីអ្វីដែលរំពឹងទុកនៅពេលដែលលោកអ្នកនិយាយទៅកាន់ពួកគេ។

## តើមានការជួយអ្វីខ្លះនៅទីនោះសំរាប់កូនៗរបស់ខ្ញុំ?

កូនៗអាចនិយាយទៅកាន់អ្នកពិគ្រោះយោបល់គ្រួសារម្នាក់ ជាផ្នែកមួយនៃកម្មវិធីជីកាបង្គាប់ឪពុកម្ដាយ។ ពួកគេក៏អាចចូលរួមក្រុមជាមួយនឹងកូនៗដទៃទៀតដែលគ្រួសាររបស់ពួកគេកំពុងជួបបទពិសោធន៍នូវបញ្ហាស្រដៀងគ្នា។ រឿងនេះជួយពួកគេអោយយល់ពីអ្វីកើតឡើងនៅក្នុង គ្រួសារ។

សេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នាគឺសំដៅជួយកូនៗតាមរយៈឪពុកម្ដាយរបស់ពួកគេ។ អង្គការខ្លះអាចផ្ដល់ការពិគ្រោះយោបល់ ឬជំនួយឯកទេស ដទៃទៀតសំរាប់កូនៗនៅក្រោមកម្មវិធីផ្សេងគ្នាមួយ ឬពួកគេ អាចស្នើសុំសេវាដទៃទៀតនៅតាមមូលដ្ឋាន។
លោកអ្នកអាចពិភាក្សាពីសេចក្ដីត្រូវការរបស់កូនលោកអ្នកជាមួយនឹងសេវានៅពេលណាមួយក៏បាន។

## តើខ្ញុំត្រូវប្រើប្រាស់កម្មវិធីជីកាបង្គាប់ឪពុកម្ដាយ ឬសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា នៅពេលណា?

តុលាការអាចលើកទឹកចិត្ត ឬបង្គាប់ឪពុកម្ដាយដើម្បីចូលរួម កម្មវិធី ឬសេវាមួយ។ លោកអ្នក ឬឪពុកម្ដាយដទៃទៀតរបស់កូនរបស់លោអ្នកអាច ត្រូវគេបញ្ជូនយោងទៅកម្មវិធីជីកាបង្គាប់ឪពុកម្ដាយ ឬសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា ដោយសេវាទំនាក់ទំនងរបស់កូនៗ ដោយមជ្ឈមណ្ឌលទំនាក់ទំនងគ្រួសារ ដោយអ្នកពិគ្រោះយោបល់គ្រួសារ ឬសេវាណាមួយដទៃទៀតដែលកំពុងជួយគ្រួសាររបស់លោកអ្នក ក្រោយពីការបែកគ្នា។ ជួនកាលឪពុកម្ដាយត្រូវធ្វើសេចក្ដីសំរេចចិត្តផ្ទាល់របស់ពួកគេ ដើម្បីទៅ កម្មវិធីជីកាបង្គាប់ឪពុក ម្ដាយ ឬសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា ដោយខ្លួនឯង។

## តើអ្វីដែលខ្ញុំនិយាយមានការសម្ងាត់ឬទេ?

មានការសម្ងាត់ នៅក្រោមមាត្រាច្បាប់គ្រួសារ រាល់អ្វីៗដែលលោកអ្នកនិយាយនៅក្នុងកម្មវិធីជីកាបង្គាប់ឪពុក ម្ដាយ ឬ សេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា នៅចំពោះមុខអ្នកពិគ្រោះយោបល់គ្រួសារ ឬអ្នកប្រតិបត្តិដំណោះស្រាយទំនាស់គ្រួសារគឺមានការសម្ងាត់– លើកលែង តែនៅក្នុងកាលៈទេសៈជាក់លាក់ណាមួយ ដូចជាដើម្បីការពារនូវការគំរាមធ្ងន់ធ្ងរមួយចំពោះជីវិត ឬសុខភាពរបស់ នរណាម្នាក់ ឬដើម្បីការពារគណៈកម្មាការនៃបទឧក្រិដ្ឋ។ អ្នកពិគ្រោះគ្រួសារ ឬ និងអ្នកប្រតិបត្តិដំណោះស្រាយទំនាស់គ្រួសារត្រូវតែរាយការណ៍ពីរំលោភបំពានកុមារ ឬប្រសិនបើមានគ្រោះថ្នាក់នៃការរំលោភបំពាន ទៅកាន់អាជ្ញាធរនានា ហើយរឿងនេះអាចត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុង កាលៈទេសៈខ្លះ។

## តើវានឹងចំណាយអស់ប៉ុន្មាន?

ជួនកាលលោកអ្នកនឹងត្រូវបានគេគិតថ្លៃឈ្នួលដើម្បីទៅរក កម្មវិធីដីកាបង្គាប់ឪពុកម្តាយ ឬសេវាសំរាប់ឪពុកម្តាយធ្វើកិច្ចសហការក្រោយការបែកគ្នា។ ចំនួនប្រាក់ដែលលោកអ្នកត្រូវបង់នឹងអាស្រ័យទៅកាលៈទេសៈខាងហិរញ្ញវត្ថុរបស់លោកអ្នក។ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងមនុស្សមានចំណូលទាប ឬកំពុងមានបទពិសោធន៍នៅក្នុងការលំបាកខាងហិរញ្ញវត្ថុ សូមប្រាប់អោយសេវាបានដឹង ដែលគេនឹងត្រូវមានការរៀបចំ ចាត់ចែងកើតមានឡើងដើម្បីអោយប្រាកដថា លោកអ្នកនៅតែអាចចូលរួមនៅក្នុងកម្មវិធីបាន។

## ការទៅតុលាការ

ប្រសិនបើលោកអ្នកសំរេចចិត្តដើម្បីទៅតុលាការដើម្បីបានសេចក្តីសំរេចចិត្តមួយស្តីពីកូនរបស់លោកអ្នក តុលាការអាចសំណូមពរ ឬបង្គាប់លោកអ្នក ឬ ឪពុកម្តាយដទៃទៀត ឬទាំងសងខាង ដើម្បីចូលរួមនៅក្នុងកម្មវិធីឪពុកម្តាយក្រោយការបែកគ្នា។ តុលាការអាចបង្គាប់អោយមានការចូលរួមនៅឯកម្មវិធីទាំងនេះ នៅពេលណាមួយនៅក្នុងអំឡុងពេលដំណើរការតុលាការ។ តុលាការក៏អាចបង្គាប់លោកអ្នក និងឪពុកម្តាយដៃទៀតដើម្បីចូលរួមនៅក្នុង ដំណើរការផ្លាស់ប្តូរដែលមានការមើលខុសត្រូវឬទំនាក់ទំនងទស្សនកិច្ចនានានៅឯសេវាទំនាក់ទំនងរបស់កូនៗ ។

ប្រសិនបើលោកអ្នក ឬឪពុកម្តាយដទៃទៀត មិនបានអនុវត្ត តាមដីកាបង្គាប់ឪពុកម្តាយទេ តុលាការអាចធ្វើដីកាបង្គាប់មួយថែមទៀតសំរាប់លោកអ្នក ដើម្បីចូលរួមនៅក្នុងកម្មវិធីឪពុកម្តាយក្រោយការបែកគ្នា។ តុលាការអាចបង្គាប់មនុស្សដែលមិនអនុវត្តតាមដីកាបង្គាប់ដើម្បីបង់ថ្លៃចំណាយខាងច្បាប់របស់ភាគីដទៃទៀត ចំពោះសំណុំរឿងបណ្តឹងនានា។

## តើខ្ញុំស្វែងរក កម្មវិធីជីកាបង្គាប់ឪពុកម្ដាយ និងសេវាសំរាប់ឪពុកម្ដាយធ្វើកិច្ចសហការក្រោយការបែកគ្នា យ៉ាងដូចម្ដេច ?

លោកអ្នកអាចហៅទូរស័ព្ទទៅ ខ្សែទូរស័ព្ទជំនួយទំនាក់ទំនងគ្រួសារតាមលេខ **1800 050 321** រវាងម៉ោង **8 ព្រឹក ដល់ ម៉ោង 8 ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សុក្រ និង ពីម៉ោង 10 ព្រឹក ដល់ ម៉ោង 4 ល្ងាច នៅថ្ងៃ សៅរ៍** (លើកលែងតែថ្ងៃឈប់សំរាកជាតិសាធារណៈ)។ ពួកគេអាចជួយលោកអ្នកស្វែងរកកម្មវិធី ឬសេវាដែលជិតបំផុត ឬស្នើរអោយទៅកាន់សេវាសមស្របដទៃទៀតដែលនៅជិតលោកអ្នក។

លោកអ្នកក៏អាចទស្សនាទំនាក់ទំនងគ្រួសារតាមអនឡាញ នៅឯ [www.familyrelationships.gov.au](http://www.familyrelationships.gov.au) ដើម្បីស្វែងរកស្ដីពី សេវាទំនាក់ទំនងគ្រួសារដទៃទៀត។